**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៧៤ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យ អតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨១៣/៨៩២ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៣១៦ អនក្រ.បក ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម សន្តិបណ្ឌិត | **ម៉ៅ ច័ន្ទតារា** | រដ្ឋលេខាធិការប្រចាំការនៃក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្តម សន្តិបណ្ឌិត | **ខាន់ ម៉ាន** | រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣.ឯកឧត្តម | **ម៉ឺន ហុន** | រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤.ឯកឧត្តម នាយឧត្តមសេនីយ៍ | **ចោ តក្តិ** | រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៥.ឯកឧត្តម | **សំ ប៊ុនណា** | រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៦.ឯកឧត្តម | **គួច ស៊ីផាន** | រដ្ឋលេខាធិការនៃក្រសួងការពារជាតិ | អនុប្រធាន |
| ៧.ឯកឧត្តម | **គីម សន្តិភាព** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៨.ឯកឧត្តម | **មាស សុខសេនសាន** | រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៩.ឯកឧត្តម | **សុខ សប្បាយណា** | រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ១០.ឯកឧត្តម | **យឿន សម្បត្តិ** | អនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១១.ឯកឧត្តម នាយឧត្តមសេនីយ៍ | **ស ថេត** | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១២.ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ | **សេង ផល្លី** | អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានមនុស្សនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៣.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហោ សំអាត** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៤.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **តុប នេត** | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៥.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ វាសនា** | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៦.ឯកឧត្តម | **ហ៊ីន យុទនា** | ប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៧.ឯកឧត្តម | **សួស ទ្រាខ្លា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៨.ឯកឧត្តម | **ឡុង សារឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រីតាមប្រព័ន្ធឌីជីថលនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៩.លោក | **ឈឹម សារ៉ែន** | ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិកនៃក្រសួងយុត្តិធម៌ | សមាជិក |
| ២០.លោក | **ស៊ឹម ស៊ីជា** | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលតុលាការនៃក្រសួងយុត្តិធម៌ | សមាជិក |

**គណៈកម្មការនេះមានភារកិច្ច ៖**

- សហការដឹកនាំលើដំណើរការនៃការរៀបចំនិងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ
- ពិនិត្យ ការរៀបចំ និងចងក្រងឯកសារគតិយុត្ត ដើម្បីកំណត់អំពីបែបបទនីតិវិធីនៃការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ ក្នុងគោលបំណងធានាការអនុវត្តឱ្យបានត្រឹមត្រូវនិងការពារទិន្នន័យឯកជនភាពរបស់បុគ្គល
- សម្របសម្រួល និងដោះស្រាយរាល់បាតុភាពនានា ដែលកើតឡើងក្នុងកំឡុងពេលអនុវត្តការងារ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការងាររៀបចំ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ជូននាយករដ្ឋមន្ត្រី
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីនាយករដ្ឋមន្ត្រី។

**ប្រការ២.-**

គណៈកម្មការអន្តរក្រសួង ដើម្បីសិក្សានិងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ មានអនុគណៈកម្មការចំនួន០២ ជាជំនួយការ ដែលមានសមាសភាពនិងភារកិច្ចដូចខាងក្រោម៖

**ក-អនុគណៈកម្មការច្បាប់** មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ប៊ុន ហុន** | រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្តម | **គីម សន្តិភាព** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣.ឯកឧត្តម | **មាស សុខសេនសាន** | រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤.ឯកឧត្តម | **សុខ សប្បាយណា** | រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ៥.ឯកឧត្តម នាយឧត្តមសេនីយ៍ | **ស ថេត** | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦.ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ | **សេខ ផល្លី** | អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានមនុស្សនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៧.ឯកឧត្តម | **ហ៊ិន យុថនា** | ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៨.លោក | **ពៅ ចាន់បុផល** | ប្រធាននាយកដ្ឋានបុគ្គលិកនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩.លោក | **ស៊ឹម ស៊ីជា** | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលតុលាការនៃក្រសួងយុត្តិធម៌ | សមាជិក |

| | | | |
|---|---|---|---|
| ១០.លោក | **ឈឹម សារ៉ន** | ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក នៃក្រសួងយុត្តិធម៌ | សមាជិក |
| ១១.លោក | **និត្យ ដារ៉ាយ៉ុទ** | នាយករងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី"តេជោ"នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២.លោក | **តាន់ ចន្ទ្ទលី** | ប្រធានក្រុមស្រាវជ្រាវនៃអគ្គលេខា-ធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

**អនុគណៈកម្មការច្បាប់មានភារកិច្ច ដូចខាងក្រោម៖**

- ធ្វើការសិក្សា ស្រាវជ្រាវរៀបចំចងក្រងឯកសារគតិយុត្ត និងនីតិវិធីសម្រាប់បម្រើឱ្យការរៀបចំអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ ដើម្បីជានាការអនុវត្តឱ្យមានភាពត្រឹមត្រូវស្របច្បាប់ជាពិសេសការការពារទិន្នន័យឯកជនភាពរបស់បុគ្គល
- សិក្សា ស្រាវជ្រាវ រៀបចំក្របខ័ណ្ឌច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តសមស្រប ដើម្បីកំណត់លក្ខខ័ណ្ឌ និងបែបបទនីតិវិធី ក្នុងការទទួលបាននីតិសម្បទាឡើងវិញចំពោះអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ
- ធ្វើរបាយការណ៍ពីលទ្ធផលការងាររបស់ខ្លួនជូនប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សានិងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនពីប្រធានគណៈកម្មការអន្តរក្រសួងនេះ។

**ខ-អនុគណៈកម្មការបច្ចេកទេស** មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម នាយឧត្តមសេនីយ៍ | **ម៉ៅ ភក្តិ** | រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្តម | **សំ ម៉ុនណា** | រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣.ឯកឧត្តម | **យឿន សម្បត្តិ** | អនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ៤.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហោ សំអាត** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ | អនុប្រធាន |
| ៥.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **គុប នេត** | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ វាសនា** | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ | សមាជិក |

| | | | |
|---|---|---|---|
| ៧.ឯកឧត្តម | **ឡុង សារឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រព័ន្ធគ្រប់គ្រងមន្ត្រីតាមប្រព័ន្ធឌីជីថល នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៨.លោក | **សុទ្ធ ឌី** | ប្រធាននាយកដ្ឋានឯកសារអេឡិចត្រូនិកនិងព័ត៌មានវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩.លោក | **មិន ភក្តុដា** | ប្រធាននាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០.លោកឧត្តមសេនីយ៍ត្រី | **កួច សុជាតិ** | នាយការិយាល័យផែនការនៃក្រសួងការពារជាតិ | សមាជិក |
| ១១.លោក | **ម៉ា ឫទ្ធិរិទ្ធ** | ប្រធានការិយាល័យចំណុះអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២.លោកឧត្តមសេនីយ៍ត្រី | **ទ្រាក់ ផានិត** | នាយរងការិយាល័យគ្រប់គ្រងឋានន្តរស័ក្តិ និងតែងតាំងផ្លាស់ប្តូរ នៃក្រសួងការពារជាតិ | សមាជិក។ |

**អនុគណៈកម្មការបច្ចេកទេសមានភារកិច្ច ដូចខាងក្រោម៖**

- ដឹកនាំ សិក្សា ស្រាវជ្រាវ រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ
- រៀបចំបង្កើតប្រព័ន្ធមួយជាស្តង់ដា និងកំណត់គោលការណ៍លើការងារផ្ទៀងផ្ទាត់ទិន្នន័យ ការពារប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ រួមទាំងប្រព័ន្ធទប់ស្កាត់ការលួចចូលបំផ្លាញទិន្នន័យ ឬការធ្វើឱ្យបែកធ្លាយនូវទិន្នន័យឯកជនភាពរបស់បុគ្គល
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃដំណើរការកសាង និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌជូនប្រធានគណៈកម្មការអន្តរក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនពីប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៣.-**

អនុគណៈកម្មការនីមួយៗ មានសិទ្ធិចាត់មន្ត្រីក្រោមឱវាទ ដើម្បីជួយការងារតាមការចាំបាច់។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុង ប្រការ១ និងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែមករា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ